ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០៥៣.......សហវ.......

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេស រៀបចំផែនការយុទ្ធសាស្ត្រដើម្បីសម្រេចបាន ការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេស រៀបចំផែនការយុទ្ធសាស្ត្រដើម្បីសម្រេចបានការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **វង្សី វិស្សុត** | រដ្ឋលេខាធិការប្រចាំការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | លោកជំទាវ **ខួន សុខា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម **ហែម វណ្ណឌី** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. | ឯកឧត្តម **ចាន់ សុធី** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. | ឯកឧត្តម **អៀង ស៊ុនលី** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. | ឯកឧត្តម **ទេព តិយ្យោវិទ្រ** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. | ឯកឧត្តម **ម៉ែន ធីរុត្ត** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨. | ឯកឧត្តម **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក |
| ៩. | ឯកឧត្តម **ហាវ រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា កសហវ | សមាជិក |
| ១០. | ឯកឧត្តម **ឈាង វណ្ណារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ កសហវ | សមាជិក |
| ១១. | ឯកឧត្តម **ឈួន សំរិទ្ធិ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល កសហវ | សមាជិក |
| ១២. | ឯកឧត្តម **ស្រី ទុច** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា កសហវ | សមាជិក |
| ១៣. | លោក **តក្កី សម្បូរណ៍** | អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក |
| ១៤. | លោក Robert Kolesar | ទីប្រឹក្សានៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក |
| ១៥. | លោកស្រី **ហេង ច័ន្ទសុតា** | ប្រធាននាយកដ្ឋានសន្តិសុខសង្គមនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | លេខាធិការ |

**ប្រការ ២ .-**

ក្រុមការងារបច្ចេកទេសនេះ មានភារកិច្ចលើកសំណើជម្រើសគោលនយោបាយសម្រាប់ការពង្រីកវិសាលភាពគ្របដណ្តប់របស់ប្រព័ន្ធថែទាំសុខភាពដើម្បីសម្រេចបានការគ្របដណ្តប់សុខភាពជាសកលដោយផ្តោតលើការងារដូចខាងក្រោម÷

- សិក្សាអំពីលទ្ធភាពកែទម្រង់ស៊ីជម្រៅប្រព័ន្ធសុខាភិបាល រួមមានការលើកកម្ពស់គុណភាពសេវា និងជំរុញការអនុវត្តយុទ្ធសាស្ត្រចំណាយ (strategic purchasing),
- សិក្សាអំពីការពង្រីកវិសាលភាពគ្របដណ្តប់ដោយផ្តល់អាទិភាពចំពោះពលរដ្ឋងាយរងគ្រោះ,

- រៀបចំកែទម្រង់ក្របខ័ណ្ឌស្ថាប័ននៃទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល និងការពង្រីកមុខងារភារកិច្ចសម្រាប់ប្រព័ន្ធថែទាំសុខភាពទាំងមូល,
- កំណត់ទំហំតម្រូវការថវិកា និងធនធានជាក់ស្តែង សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រដើម្បីសម្រេចបានការគ្របដណ្តប់សុខភាពជាសកល,
- បំពេញការងារផ្សេងទៀតដែលកំណត់ដោយថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣ .-**

សមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចដើម្បីចូលរួមជំនួស ក្នុងករណីអវត្តមាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិរបស់ប្រធាន។

ក្រុមការងារបច្ចេកទេសនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា តំណាងដៃគូអភិវឌ្ឍន៍ និងតំណាងវិស័យឯកជន ចូលរួមប្រជុំតាមការចាំបាច់ និងអាចស្នើសុំកិច្ចសម្របសម្រួលនិងសហប្រតិបត្តិការពីគ្រប់ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន ដទៃទៀត។

**ប្រការ ៤ .-**

នាយកដ្ឋានសន្តិសុខសង្គមនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម បំពេញមុខងារជាលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសនេះ។

**ប្រការ ៥ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានគោលនយោបាយ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១ កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ដូចប្រការ ១
- ឯកសារ-កាលប្បវត្តិ